FIRST FINANCE

# ដៃគូដំណោះស្រាយ ហិរញ្ញវត្ថុផ្នែក លំនៅដ្ឋាន

របាយការណ៍ប្រចាំឆ្នាំ ២០២០



# មាតិកា

០៤. សាររួមពី អគ្គនាយិកា និង ប្រធានក្រុមប្រឹក្សាភិបាល
០៦. អំពី ហ្វីស ហ្វាយនែន
០៨. សមិទ្ធផលរបស់យើង
១០. អំពីផលិតផល
១១. តំបន់ប្រតិបត្តិការ
១២. ដៃគូវិនិយោគរបស់យើង
១៣. រចនាសម្ព័ន្ធ ហ្វីស ហ្វាយនែន
១៤. ការអភិវឌ្ឍជាប្រចាំ
១៦. រឿងរបស់អតិថិជន
១៨. របាយការណ៍របស់សវនករឯករាជ្យ
២០. របាយការណ៍ហិរញ្ញវត្ថុ
២៤. រឿងរបស់អតិថិជន
២៦. ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំ

តួរលេខក្នុងរបាយការណ៍នេះ គឺរបស់ ហ្វីស ហ្វាយនែន សម្រាប់ការិយបរិច្ឆេទ 01 មករា 2020 ដល់ 31 ធ្នូ 2020





# សាររួមពីអគ្គនាយិកា និង ប្រធានក្រុមប្រឹក្សាភិបាល

ការរីករាលដាលនៃជំងឺ កូវីដ 19 បានធ្វើអោយឆ្នាំ 2020 ក្លាយជាឆ្នាំដែលមានការប្រឈមខ្ពស់សម្រាប់អតិថិជន បុគ្គលិក និងអ្នកដែលពាក់ពន្ធ័ផ្សេងទៀតរបស់យើង ។ ទោះបីជាករណីកើតជម្ងឺកូវីដ១៩ ក្នុងប្រទេសកម្ពុជាមានចំនួនទាប បើប្រៀបធៀបជាមួយបណ្ដាប្រទេសជិតខាង អ្នកដែលប្រកបរបរអាជីវកម្មខ្នាតតូចជាច្រើនបានរងផលប៉ះពាល់លើមុខរបរ និងចំណូលរបស់ពួកគាត់ ។ ចាប់ពីខែមីនា ឆ្នាំ 2020 មក វិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុ ក្នុងប្រទេសកម្ពុជាបានឆ្លើយតបបានយ៉ាងល្អ ទៅនឹងផលប៉ះពាល់ដែលបណ្ដាលមកពីវិបត្តិកូវីដ ។ ជាលទ្ធផល ឥណទានចំនួន 25 ម៉ឺន ដែលមានតម្លៃជាទឹកប្រាក់ប្រមាណជាង 3,500 លានដុល្លារអាមេរិក ត្រូវបានរៀបចំឡើងវិញ ។ គួរអោយសោកស្ដាយ វិបត្តិកូវីដនៅតែអូសបន្លាយ ដូច្នេះផលប៉ះពាល់នៅតែបន្តមានចំពោះជីវភាពរស់នៅរបស់គ្រួសារប្រជាជនកម្ពុជា។

ចាប់តាំងពីពេលចាប់ផ្ដើម នៃការរីករាលដាលជំងឺកូវីដ១៩ ហ្វីសហ្វាយនែន បានខិតខំប្រឹងប្រែងជួយគាំទ្រដល់អតិថិជនក្នុងការជួយដោះស្រាយបញ្ហាក្នុងពេលដ៏លំបាកនេះ ។ គណៈគ្រប់គ្រងរបស់យើងបានសម្រេចចិត្តភ្លាមៗ ក្នុងការផ្លាស់ប្ដូរគោលដៅពីការផ្ដោតលើការបង្កើនផលប័ត្រឥណទាន មកជាការជួយជ្រោមជ្រែងអតិថិជន ដោយផ្ដល់ជាប្រឹក្សាទាក់ទងនឹង មេរោគកូរ៉ូណា និងវិធីសាស្ត្រដែលសមស្របក្នុងការកែសម្រួលការបង់សងអោយស្របទៅតាមស្ថានភាពចំណូលដែលកំពុងធ្លាក់ចុះ ។ ជំនួសអោយការបង្ខំអតិថិជនឲ្យមានការយឺតយ៉ាវលើការបង់កម្ចីរបស់ពួកគាត់ យើងបានអនុញ្ញាតិអោយអតិថិជនបន្ថយចំនួនប្រាក់បង់ប្រចាំខែក្នុងចំនួនមួយដែលពួកគាត់អាចទៅរួច ។ យើងបានរៀបចំឥណទានឡើងវិញ ដើម្បីបន្ថយចំនួនបង់ប្រចាំខែ ជូនដល់អតិថិជនដែលរងផលប៉ះពាល់ដោយវិបត្តិកូវីដប្រមាណ 150 នាក់ ជាមួយកម្ចីប្រហែល 200 គណនី ដែលសរុបជាទឹកប្រាក់ប្រមាណ 2,7 លានដុល្លារ ។

ខណៈពេលដែលយើងកំពុងផ្ដោត លើការគ្រប់គ្រងផលប៉ះពាល់ពីវិបត្តិកូវីដ ជាមួយគ្នានេះដែរ យើងក៏នៅតែបន្តផ្ដល់សេវាជាធម្មតាជូនដល់អតិថជនរបស់យើង ក្នុងនាមជាដៃគូរយៈពេលវែង ដែលភាគច្រើននៃពួកគាត់មានកម្ចីលំនៅដ្ឋានរយៈពេលចាប់ពី 15 ទៅ 20 ឆ្នាំ ។ យើងបានអនុវត្តនីតិវិធីសិក្សាកម្ចីប្រកបដោយភាពច្នៃប្រឌិត ដោយផ្ដល់នូវការប្រឹក្សាលើផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ រាប់ចាប់ពីដំណាក់កាលដំបូង រហូតដល់មួយវដ្ដនៃកម្ចីដែលពួកគាត់នៅជាមួយយើង ។ យើងជឿជាក់ថា ការធ្វើបែបនេះ

នឹងធ្វើអោយជម្រើសរបស់ពួកគាត់ក្នុងការចូលរួមជាមួយ គ្រួសារ ហ្វីស ហ្វាយនែន គឺជាការសម្រេចចិត្តដ៏ត្រឹមត្រូវមួយ ។

យើងប្តេជ្ញាខ្ពស់ចំពោះគោលការណ៍ការពារអតិថិជន របស់យុទ្ធនាការ Smart ហេតុដូចនេះហើយ យើងបានផ្តល់នូវការយកចិត្តទុកដាក់ និងតម្លាភាពខ្ពស់ចំពោះអតិថិជន ។ យើងបានអនុវត្តកម្មវិធីពិសេសដែលលើកទឹកចិត្តបុគ្គលិកតាមសាខាក្នុងការកសាងទំនាក់ទំនងល្អជាមួយអតិថិជន ចាប់តាំងពីដំណាក់កាលដំបូង រហូតដល់រយៈពេលពេញមួយវដ្តនៃកម្ចី ។ តាមរយៈការស្ទង់មតិយោបល់អតិថិជនជាទៀងទាត់ ព្រមជាមួយការអនុវត្តន៍តាមគោលការណ៍ដ៏ហ្មត់ចត់ក្នុងការដោះស្រាយបណ្តឹង ជាលទ្ធផលយើងអាចធ្វើការអភិវឌ្ឍគោលនយោបាយផ្ទៃក្នុង និងអភិវឌ្ឍផលិត-ផលបានកាន់តែប្រសើរឡើងថែមទៀត ។

យើងនៅតែបន្តចូលរួមចំណែកក្នុងការធ្វើអោយមានផលប៉ះពាល់ជាវិជ្ជមានដល់សង្គម ដោយយើងបានជួយប្រជាជនប្រមាណ 1,500 គ្រួសារ មានលទ្ធភាពទិញផ្ទះ សាងសង់ និងជួសជុលផ្ទះ ។ អតិថិជនជាស្ត្រីមានប្រមាណ 60% នៃអតិថិជនសរុប ហើយ 50% នៃអតិថិជនរបស់យើង ត្រូវបានចាត់ទុកថាជាអ្នកដែលមានចំណូលទាប ដោយពួកគាត់មានចំណូលក្រោម 700 ដុល្លារក្នុង ១ខែ ។

ជាផ្នែកមួយនៃការអភិវឌ្ឍសេវាអតិថិជនអោយកាន់តែប្រសើរឡើងថែមទៀត ក្នុងឆ្នាំ 2020 ផ្នែកព័ត៌មានវិទ្យាបានអភិវឌ្ឍទៅលើប្រពន្ធ័ពង្រឹងផ្នែកសន្តិសុខ និងអភិវឌ្ឍដំណើរការវាយតម្លៃឥណទានអោយទៅជាដំណើរការឌីជីថល។ លើសពីនេះ យើងនៅតែបន្តពង្រឹងសមត្ថភាពបុគ្គលិករបស់យើង តាមរយៈការផ្តល់វគ្គសិក្សាបច្ចេ-កទេសផ្នែកសេវាហិរញ្ញវត្ថុ ក៏ដូចជាផ្នែកប្រាស្រ័យទាក់ទង ។ ជាមួយគ្នានេះដែរ គ្រប់បុគ្គលិកដែលចូលថ្មីត្រូវបានឆ្លងកាត់វគ្គបំពាក់បំប៉នផងដែរ ។

ហ្វីស ហ្វាយនែន មានគ្រប់នីតិវិធី និងគោលការណ៍ផ្សេងៗសម្រាប់គ្រប់គ្រង និងបញ្ចៀសហានិភ័យ ។ នីតិវិធីវាយតម្លៃសិក្សាឥណទានត្រូវបានត្រួតពិនិត្យជាប្រចាំ និងធ្វើការកែប្រែបើចាំបាច់ ដើម្បីអោយស្របទៅនឹងស្ថានភាពទីផ្សារ និងហានិភ័យដែលយើងបានជួបប្រទះ ។ ការគ្រប់គ្រងហានិភ័យ ត្រូវបានចូលរួមចំណែកពីក្រុមវាយតម្លៃអចលនទ្រព្យដែលពោរពេញទៅដោយបទពិសោធន៍ខ្ពស់ យល់ដឹងពីនិន្នាការថ្មីៗនៃការអភិវឌ្ឍអចលន-ទ្រព្យ ក៏ដូចជាបទពិសោធន៍ក្នុងការវាយតម្លៃលើប្រភេទផ្ទះជាច្រើន នៅកន្លែងផ្សេងៗក្នុងទីក្រុងភ្នំពេញ ក៏ដូចជាផ្នែកផ្សេងទៀតនៃប្រទេសកម្ពុជា ។ ហានិភ័យសាច់ប្រាក់ និងចរន្តសាច់ប្រាក់ត្រូវបានត្រួតពិនិត្យ និងនាំយកទៅពិភាក្សាជាប្រចាំក្នុងគណៈកម្មការគ្រប់គ្រងទ្រព្យសម្បត្តិ និងបំណុល ក៏ដូចជាក្រុមប្រឹក្សាភិបាលរបស់យើង ។ ការពិភាក្សាទាន់ពេលវេលាជាមួយស្ថាប័នម្ចាស់បំណុលថ្មីក្តី និងចាស់ក្តី អាចអោយយើងធានាបានថា យើងមានប្រាក់ទុនគ្រប់គ្រាន់ ជាមួយតម្លៃសមរម្យសម្រាប់គាំទ្រដល់ការរីកចម្រើនផលបត្រឥណទានរបស់យើងបានក្នុងរយៈពេលវែង ។

ដោយសារវិបត្តិកូវីដ១៩ ក្នុងឆ្នាំ 2020 ហ្វីស ហ្វាយនែន មិនបានបង្កើនផលប័ត្រឥណទាន ទៅតាមផែនការនោះទេ ក៏ប៉ុន្តែយើងទទួលបានជោគជ័យក្នុងការគ្រប់គ្រងហានិភ័យឥណទាន ដោយរក្សាវាអោយស្ថិតក្នុងកម្រិតមួយដែលអាចទទួលយកបាន ។ យើងទទួលបានប្រាក់ចំណូលប្រមាណ 1,8 លានដុល្លារ និងប្រាក់ចំណេញប្រមាណ 9,7មុឺន ដុល្លារ គឺប្រហាក់ប្រហែលនឹងឆ្នាំមុន ។ យើងចាត់ទុកថា វាគឺជាជោគជ័យមួយ ដែលសម្រេចបានក្នុងកាលៈទេសៈដ៏តឹងតែងបែបនេះ ។

ក្នុងនាមជាស្ថាប័នមួយ ក្នុងចំណោមស្ថាប័នដ៏តិចតួចនៅក្នុងប្រទេសកម្ពុជា ដែលផ្តល់ឥណទានលំនៅដ្ឋានខ្នាតតូច ហ្វីស ហ្វាយនែន នៅតែរក្សាជំហរក្នុងការផ្តល់កម្ចីរយៈពេលវែងដល់អ្នកដែលមានចំណូលទាប និងមធ្យម ដើម្បីអោយគាត់មានលទ្ធភាពទិញផ្ទះជារបស់ផ្ទាល់ខ្លួនក្នុងតម្លៃសមរម្យ និងរស់នៅក្នុងជីវភាពមួយប្រកបដោយស្ថេរភាព ។ យើងជឿជាក់ថា យើងនឹងអាចពង្រីកផលបត្រឥណទាន និងបង្កើតសមិទ្ធផលរបស់យើងអោយកាន់តែប្រសើរឡើងសម្រាប់ឆ្នាំ 2021 ដោយយើងមើលឃើញពីការគាំទ្រពីរាជរដ្ឋាភិបាល និងការចូលរួមពីអ្នកអភិវឌ្ឍអចលនទ្រព្យជាច្រើន ដែលបានងាកទៅរកការអភិវឌ្ឍន៍លំនៅដ្ឋានដែលមានតម្លៃសមរម្យ នៅតំបន់ជុំវិញរាជធានីភ្នំពេញ ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអតិថិជន បុគ្គលិក ម្ចាស់បំណុល ដៃគូអាជីវកម្ម និងអ្នកពាក់ពន្ធ័ដ៏ទៃផ្សេងទៀតដែលបានចូលរួមចំណែកចំពោះលទ្ធផលជោគជ័យរបស់ ហ្វីស ហ្វាយនែន ។

# អំពី ហ្វីស ហ្វាយនែន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី គឺជាក្រុមហ៊ុនដែលបណ្តាក់ទុនរួមគ្នារវាង ក្រុមហ៊ុន ហ្វីស ហូម ភីអែលស៊ី ដែលមានទីតាំងក្នុងប្រទេសកម្ពុជា Phillip Capital ដែលមានទីតាំងក្នុងប្រទេសសិង្ហបុរី Insitor Fund ដែលមានទីតាំងក្នុងប្រទេសលុចសំបួរ មូលនិធិអភិវឌ្ឍន៍កម្ពុជា ឡាវ ( Cambodia-Laos Development Fund ) និង Norfund ដែលមានទីតាំងក្នុងប្រទេសន័រវេស។ ហ្វីស ហ្វាយនែន បានទទួលអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា នៅថ្ងៃទី23 ខែមេសា ឆ្នាំ2009 ហើយបានក្លាយជាគ្រឹះស្ថានហិរញ្ញវត្ថុឯកទេស ក្នុងការផ្តល់ឥណទានផ្ទះសម្បែងមុនគេក្នុងប្រទេសកម្ពុជា។ ហ្វីស ហ្វាយនែន ផ្តោតយ៉ាងខ្លាំងទៅលើការផ្តល់ប្រាក់កម្ចីទិញផ្ទះ និងសាងសង់ផ្ទះរយៈពេលវែងក៏ដូចជាកម្ចីអចលទ្រព្យធានារយៈពេលមធ្យម ទៅដល់គ្រួសារដែលមានចំណូលទាប និងមធ្យម ដែលភាគតិចណាស់ មានលទ្ធភាពប្រើប្រាស់សេវាកម្ចីលំនៅដ្ឋានរបស់គ្រឹះស្ថានហិរញ្ញវត្ថុផ្លូវការនានា។ ភាគច្រើននៃធនាគារពាណិជ្ជផ្តល់សេវាដល់អតិថិជនដែលមានចំណូលខ្ពស់ ។

ក្រុមហ៊ុន ហ្វីស ហូម ភីអិលស៊ី ដែលជាក្រុមហ៊ុនស្ថាបនិក ហ្វីស ហ្វាយនែន បានធ្វើការសាកល្បង និងបានធ្វើឲ្យកាន់តែប្រសើរឡើងនូវគំនិតផ្តួចផ្តើមដំបូង ក្នុងការការផ្តល់ឥណទានផ្ទះសម្បែង ព្រមទាំងបានធ្វើការសិក្សាជាច្រើនទៅលើតម្រូវការទីផ្សារសម្រាប់ផលិតផលនេះ។ ទាំងនេះគឺជាមូលដ្ឋានគ្រឹះដែលនាំឲ្យ ហ្វីស ហ្វាយនែន រីកចម្រើនទៅមុខយ៉ាងឆាប់រហ័ស។

## ទស្សនៈវិជ្ជាអាជីវកម្មរបស់យើង

ទស្សនៈវិជ្ជាអាជីវកម្មរបស់យើងមានភាពសាមញ្ញ៖ **យើងគិតដូចជាអតិថិជន និងអនុវត្តដូចជាម្ចាស់**

ផ្តល់សេវានិងផលិតផល
ដែលឆ្លើយតបទៅនឹង
តម្រូវការទីផ្សារ

ផ្តល់នូវនីតិវិធីដែល
មានភាព រហ័ស
និងងាយស្រួល

ធ្វើប្រតិបត្តិការប្រកប
ដោយភាពបត់បែន
និងមានតម្លាភាព

បង្ហាញពីភាពសុចរិត
ទៀងត្រង់ និងសីលធម៌
ក្នុងការអនុវត្តអាជីវកម្ម

## ចក្ខុវិស័យរបស់យើង

ជួយឲ្យក្រុមគ្រួសារនៅក្នុងប្រទេសកម្ពុជាដែលមានចំណូលមធ្យមកម្រិតទាប បានរស់នៅក្នុងសេចក្តីថ្លៃថ្នូរ សុវត្ថិភាព សុភមង្គល និងមានស្ថេរភាព តាមរយៈការផ្តល់លទ្ធភាពឲ្យពួកគាត់មានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន

## បេសកកម្មរបស់យើង

បង្កើតស្ថេរភាពសេដ្ឋកិច្ចនៃគ្រួសារកម្ពុជាដែលមានចំណូលមធ្យមកម្រិតទាប តាមរយៈការផ្តល់សេវាឥណទានដើម្បីឲ្យពួកគាត់ក្លាយជាម្ចាស់កម្មសិទ្ធិនៃផ្ទះសម្បែង

## គុណតម្លៃរបស់យើង

**សុចរិតភាព**
ដើម្បីសម្រេចបាននូវចក្ខុវិស័យរបស់យើង យើងប្រកាន់ខ្ជាប់នូវភាពស្មោះត្រង់ និងមានតម្លាភាពគ្រប់សកម្មភាពការងាររបស់យើង ។

**ការឆ្លើយតប**
យើងតែងនៅកៀកស្និទ្ធជាមួយអតិថិជនគ្រប់គ្រាន់ល្មម ដែលអាចឲ្យយើងផ្តល់ការយកចិត្តទុកដាក់ និងឆ្លើយតបតម្រូវការរបស់ពួកគាត់ទាន់ពេលវេលា ។ យើងក៏មានទំនួលខុសត្រូវគ្រប់ទង្វើរបស់យើង និងបើកចិត្តទូលាយក្នុងការទទួលយកការិះគន់ដើម្បីស្ថាបនាផងដែរ ។

**ភាពច្នៃប្រឌិតខ្ពស់**
យើងមានគំនិតច្នៃប្រឌិតខ្ពស់ក្នុងការស្វែងរកដំណោះស្រាយដែលមានប្រសិទ្ធិភាពដើម្បីបម្រើអតិថិជនរបស់យើងឲ្យកាន់តែប្រសើរជាងមុន ។

**ភាពស្មើគ្នា**
យើងមានមោទនភាពចំពោះការគោរព ការមានជំនាញវិជ្ជាជីវៈច្បាស់លាស់ និងការបម្រើដល់អតិថិជនដោយស្មើភាព។

**ឧត្តមភាព**
ការងាររបស់យើង គឺធ្វើឡើងដោយអស់ពីកម្លាំងកាយចិត្ត។

# សមិទ្ធផលរបស់យើង

ហ្វីស ហ្វាយនែន ជឿជាក់ថាការជួយអោយមនុស្សមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន គឺជាកត្តាសំខាន់ក្នុងការជួយអោយពួកគាត់មានជីវិតប្រសើរឡើង ។ ស្ថេរភាពនៃការដែលមានផ្ទះផ្ទាល់ខ្លួន អាចជួយអោយគ្រួសារបានចំណាយពេលវេលា និងថាមពលទៅលើកត្តាផ្សេងទៀតដែលសំខាន់សម្រាប់ជីវិត ក្មេងៗអាចចំណាយពេលសិក្សារៀនសូត្រ ចំណែកឯស្ត្រីអាចចាប់យករបរផ្សេងៗ ឬបម្រើការងារ ។ ទាំងនេះអាចជួយអោយទំនាក់ទំនងរវាងអ្នកជិតខាង និងសហគមន៍ក៏កាន់តែរឹងមាំ ។ ទំនាក់ទំនងដែលរឹងមាំនេះហើយ ដែលនាំមកនូវការគោរពរវាងគ្នានៅក្នុងគ្រួសារ ។ ការដែលមានផ្ទះជាកម្មសិទ្ធខ្លួន មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងអត្តសញ្ញាណបុគ្គល ។ សុវត្ថិភាព និងសន្តិសុខរបស់គ្រួសារនឹងកាន់តែកើនឡើង នៅពេលដែលពួកគាត់មានផ្ទះជាកម្ម-សិទ្ធិផ្ទាល់ខ្លួន ។

2020 ជាឆ្នាំដែល ហ្វីស ហ្វាយនែន ជួបនូវឧបសគ្គក្នុងការរីកចំរើន និងការធ្វើប្រតិបត្តិការ ។ វិបត្តិកូវីដ គឺជាចំណែកសំខាន់នៃឧបសគ្គនេះ ។ ទោះបីជាបែបនេះក្តី ក៏យើងនៅតែបន្តប្តេជ្ញាចិត្ត ជួយដល់ក្រុមគ្រួសារដែលមានចំណូលទាប និងមធ្យម ដែលត្រូវបានគេមើលរំលង ដើម្បីអោយពួកគាត់មានលទ្ធភាពបង្កើតនូវទ្រព្យធន និងមានស្ថេរភាពនៅក្នុងគ្រួសារ ។

គិតត្រឹមចុងឆ្នាំ 2020 យើងមានផលបត្រឥណទានចំនួន 23.06 លានដុល្លារ ថយចុះប្រមាណ 7% ធៀបនឹងចុងឆ្នាំ 2019 ។ អតិថិជនដែលមានចំណូលតិចជាង 300 ដុល្លារក្នុង 1ខែ មានប្រមាណ 8.95% នៃអតិថិជនសរុប ចំណែកឯអតិថិជនមានចំណូលចន្លោះ 300 ទៅ 700 ដុល្លារក្នុង ១ ខែ មានប្រមាណជាង 41.29% ខណៈអតថិជនដែលមានចំណូលលើលពី 700 ដុល្លារក្នុង ១ ខែ មាន 49.76% ។ ចំនួនអតិថិជនដែលជាស្ត្រីមានចំនួន 62% នៃអតិថិជនសរុប ។ បើទោះបីជួបវបត្តិនេះក៏ដោយ ក៏យើងនៅតែអាចគ្រប់គ្រងបានល្អ ទៅលើផលបត្រឥណទានដែលមិនដំណើរ ។ ជាលទ្ធផលអត្រាផលបត្រឥណទានមិនដំណើរការបានកើនឡើងបន្តិចពី 2.14% ក្នុងឆ្នាំ 2019 ទៅ 3.03% នៅក្នុងឆ្នាំ 2020 ក្នុងខណៈនោះដែរ បំណុលដែលបានបាត់បង់ បានប្រមូលមកវិញចំនួន 41.54% នៃបំណុលដែលបានបាត់បង់សរុប គិតត្រឹមខែធ្នូ ឆ្នាំ 2020 ។

## ផលបត្រឥណទាន តាមប្រវត្តិអតិថិជន



## ភាគរយអតិថិជនតាមប្រភពចំណូល




## ភាគរយអតិថិជនតាមទំហំចំណូលប្រចាំខែ




## ភាគរយអតិថិជនតាមភេទ




## ចំនួនអតិថិជនសកម្មសរុប



1,487

# អំពីផលិតផល

ហ្វ៊ីស ហ្វាយនែន ជាគ្រឹះស្ថាមីក្រូហិរញ្ញវត្ថុដែលមានអាជ្ញាបណ្ណ័ និងជាគ្រឹះស្ថានឯកទេសក្នុងការផ្តល់កម្ចីលំនៅដ្ឋានខ្នាតតូចដំបូងគេនៅកម្ពុជា ។ យើងផ្តល់កម្ចីទិញផ្ទះ ទិញដី សាងសង់និងជួសជុលផ្ទះរយៈពេលវែង ក៏ដូចជាកម្ចីអចលនទ្រព្យធានារយៈពេលមធ្យម ដល់ប្រជាជនកម្ពុជាដែលមានចំណូលទាប និងមធ្យម ដែលប្រឈមនឹងការលំបាកក្នុងការទទួលបានសេវានេះពីស្ថាប័នហិរញ្ញវត្ថុផ្លូវការ ។

គិតត្រឹមថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2020 យើងបានផ្តល់សេវាកម្ចីដល់ប្រជាជនចំនួន 1,487 គ្រួសារ ជាមួយផលបត្រឥណទានប្រមាណ 23.06 លានដុល្លារ ។

---

**កម្ចីទិញផ្ទះ**

**32.6%** នៃចំនួនផលបត្រឥណទានសរុប

**439** ចំនួនប្រាក់កម្ចីសកម្ម

---

**703** ចំនួនប្រាក់កម្ចីសកម្ម

**27.7%** នៃចំនួនផលបត្រឥណទានសរុប

**កម្ចីសាងសង់ ជួសជុលផ្ទះ**

---

**កម្ចីទិញដី លំនៅដ្ឋាន**

**20.2%** នៃចំនួនផលបត្រឥណទានសរុប

**440** ចំនួនប្រាក់កម្ចីសកម្ម

---

**606** ចំនួនប្រាក់កម្ចីសកម្ម

**19.3%** នៃចំនួនផលបត្រឥណទានសរុប

**កម្ចីអចលនទ្រព្យធានា**

*កម្ចីអចលនទ្រព្យធានា ផ្តល់ជូនសម្រាប់តែអតិថិជនប៉ុណ្ណោះ*

# តំបន់ប្រតិបត្តិការ



# ដៃគូវិនិយោគ

## មូលធន



Norfund
www.norfund.no
15.09%

www.firstfinance.biz
9.15%

CLDF Cambodia-Laos Development Fund
www.emergingmarkets.asia
19.49%

INSITOR FUND
www.insitormanagement.com
28.87%

PhillipCapital Your Partner In Finance
www.phillip.com.sg
27.41%

## ឥណទាន

OIKO CREDIT
www.oikocredit.coop

symbiotics
www.symbioticsgroup.com

BlueOrchard
www.blueorchard.com

Norfund
www.norfund.no

TripleJump
www.triplejump.eu

WATEREQUITY
www.waterequity.org

PhillipBank Your Partner In Finance
www.phillipbank.com.kh

PPCBank
www.ppcbank.com

lendahand
www.lendahand.com

# រចនាសម្ព័ន្ធ ហ្វឺស ហ្វាយនែន



# អភិវឌ្ឍន៍ជាប្រចាំ

## ការគាំទ្រអតិថិជន

យើងសង្ឃឹមថា យើងបានផ្សារភ្ជាប់បានច្រើនទៅនឹងជីវិតប្រចាំថ្ងៃរបស់អតិថិជនយើង ។ កម្រិរយៈពេល 20 ឆ្នាំ គឺជាការប្តេជ្ញាចិត្តដ៏វែងឆ្ងាយមួយ ។ ហ្វីស ហ្វាយនែន ស្វែងយល់ថា ក្នុងដំណើរដ៏វែងឆ្ងាយនេះ ក្រុមគ្រួសារនីមួយៗអាចនឹងជួបនូវឧបសគ្គលំបាកមួយចំនួន ដូចជាជម្ងឺដង្កាត់ផ្សេងៗ និងការបាត់បង់ចំណូលដោយមូលហេតុណាមួយជាក់ជាពុំខាន ។

ក្នុងវិបត្តិ កូវីដ យើងបានតាំងចិត្តខ្ពស់ក្នុងការជួយជ្រួមជ្រែងទៅដល់អតិថិជនរបស់យើងដែលជួបការលំបាក ដោយអាជីវកម្មរបស់គាត់ទទួលរងការប៉ះពាល់ពីវិបត្តិនេះ ដែលបណ្តាលអោយពួកគាត់ជួបនូវវិបត្តិហិរញ្ញវត្ថុរយៈពេលខ្លី។ យើងបានអនុម័តលើការស្នើរសុំបន្ធូរបន្ថយលើការបង់សងប្រចាំខែរបស់អតិថិជនចំនួន 150 គ្រួសារ ជាមួយកម្ចីប្រហែល 200 គណនី ស្មើរនឹងទឹកប្រាក់ 2.7 លានដុល្លារ ។

យើងកំពុងពិនិត្យលើគម្រូប្រកបដោយភាពច្នៃប្រឌិតមួយ ដើម្បីសិក្សាវាយតម្លៃទៅលើគ្រួសារអតិថិជន ព្រមជាមួយការផ្តល់ប្រឹក្សា នៅដំណាក់កាលដំបូងដែលពួកគាត់ចាប់ផ្តើមវិនិយោគ ក៏ដូចជាក្នុងកំឡុងពេលដែលពួកគាត់នៅជាមួយយើងពេញមួយវដ្តនៃកម្ចី។ ការធ្វើបែបនេះ ដើម្បីប្រាកដថាការសម្រេចចិត្តជ្រើសរើសប្រើសេវារបស់យើងគឺជាជម្រើសដ៏ត្រឹមត្រូវមួយ។ យើងបានប្តេជ្ញាចិត្តអនុវត្តគោលការណ៍ការពារអតិថិជនដែលវាមានសារៈប្រយោជន៍ដល់យើង ជាពិសេសអតិថិជន ពីព្រោះយើងបានផ្តល់សេវាប្រកបដោយការយកចិត្តទុកដាក់ និងពោរពេញទៅដោយតម្លាភាព ទៅគ្រប់អតិថិជន ។ យើងក៏បានលើកទឹកចិត្តបុគ្គលិក អោយមានប្រាស្រ័យទាក់ទងល្អជាមួយអតិថិជនតាមរយៈការបង្កើតកម្មវិធី បុគ្គលិកឆ្នើមផ្នែកកសាងទំនាក់ទំនងល្អជាមួយអតិថិជន (Client Engagement Champions) ។ បន្ថែមលើនេះ យើងតែងតែប្រមូលមតិយោបល់អតិថជនការស្ទង់មតិ និងការរិះគន់ដើម្បីយកមកអភិវឌ្ឍបន្ថែមទៅលើគោលនយោបាយ ក៏ដូចជាលក្ខខណ្ឌរបស់ផលិតផលអោយកាន់តែប្រសើរឡើងថែមទៀត ។ ការផ្សារភ្ជាប់ជាមួយអតិថិជនជាលក្ខណៈបុគ្គលបានក្លាយជាចំនុចពិសេសដែលធ្វើអោយ ហ្វីស ហ្វាយនែន ខុសប្លែកពីស្ថាប័នដ៏ទៃ ។

## ប្រត្តិបត្តិការអាជីវកម្មដោយស្វ័យប្រវត្តិ

នាយកដ្ឋានព័ត៌មានវិទ្យាបានផ្តល់ការគាំទ្រដែលចាំបាច់ លើផ្នែកប្រពន្ធ័ព័ត៌មានសម្រាប់ការគ្រប់គ្រង ការថែទាំរចនាសម្ពន្ធ័ដែលមានស្រាប់ និងបង្កើនសុវត្ថិភាពផ្នែកព័ត៌មានវិទ្យា ។ ក្នុងរយៈពេលកន្លងមកនេះ នាយកដ្ឋានបានធ្វើបច្ចុប្បន្នភាពនៅក្នុងប្រពន្ធ័ ដូចជាការស្នើសុំប្រវត្តិឥណទាន (CBC enquiry) គម្រូឯកសារផ្លូវច្បាប់ ការប្រមូលកម្ចីដែលបាត់បង់។ បន្ថែមលើនេះ នាយកដ្ឋានព័ត៌មានវិទ្យាបានអភិវឌ្ឍន៍ឧបករណ៍/របាយការណ៍មួយចំនួនដើម្បីជួយសម្រួលការងារប្រចាំថ្ងៃក្នុងការបញ្ចូលទិន្នន័យអោយកាន់តែលឿនជាងមុន ។



# ការបណ្តុះបណ្តាល និងអភិវឌ្ឍន៍

ការរៀនសូត្រគ្មានទីបញ្ចប់ទីនោះទេសម្រាប់គ្រប់គ្នា! ផ្នែកបណ្តុះបណ្តាល និងអភិវឌ្ឍន៍របស់ ហ្វីស ហ្វាយនែន មានក្រុមការងារដែលមានបទពិសោធន៍ និងត្រៀមខ្លួនរួចរាល់ដើម្បីកសាងសមត្ថភាពបុគ្គលិកគ្រប់កម្រិត តាមរយៈការបណ្តុះបណ្តាលទាំងខាងក្នុង និងខាងក្រៅស្ថាប័ន ។ ផ្នែកបណ្តុះបណ្តាល និងអភិវឌ្ឍន៍បានផ្តល់វគ្គបណ្តុះបណ្តាលជំនាញដល់បុគ្គលិកដែលចូលថ្មីចំនួន ១០នាក់ និងបុគ្គលិកចាស់ចំនួន 59 នាក់ផ្សេងទៀតដែលមកពីគ្រប់សាខាទូទាំងប្រទេស ។ ក្នុងរយៈពេលមួយឆ្នាំនេះ វគ្គសិក្សាត្រូវបានផ្តល់ដោយអ្នកបណ្តុះបណ្តាលខាងក្នុងស្ថាប័ន ដែលវគ្គទាំងនោះផ្តោតលើចំណេះដឹងផ្នែកផលិតផល គោលការណ៍ផ្សេងៗ និង មគ្គុទ្ទេសក៍ក្នុងការលក់។ ដោយសារវិបត្តិ កូវីដ បុគ្គលិកមួយចំនួនដែលទទួលវគ្គបណ្តុះបណ្តាលពីខាងក្រៅ គឺធ្វើឡើងតាមរយៈអនឡាញ ។

# ការពង្រឹងលើគុណភាព

ដោយសារការកើនឡើងជាបន្តបន្ទាប់នៃវិស័យហិរញ្ញវត្ថុ ក៏ដូចជាការកើតឡើងនូវហានិភ័យថ្មីៗ ហ្វីស ហ្វាយនែន បានផ្តោតការយកចិត្តទុកដាក់ខ្ពស់ទៅលើការគ្រប់គ្រងហានិភ័យរបស់ខ្លួន ។ យើងបានធ្វើបច្ចុប្បន្នភាពលើគោលនយោបាយ និងដំណើរការវាយតម្លៃឥណទានជាប្រចាំឆ្នាំ ។ ជាមួយគ្នានេះដែរយើងក៏បានពង្រឹងនូវសមត្ថភាពជំនាញវាយតម្លៃឥណទាន របស់មន្ត្រីវាយតម្លៃឥណទានតាមរយៈការផ្តល់នូវវគ្គបណ្តុះបណ្តាលជាប្រចាំ ។ម៉្យាងទៀត ដោយសារតែមុខងារក្នុងនាយកដ្ឋានឥណទានត្រូវបានបំពេញពេញលេញកាលពីឆ្នាំកន្លងទៅ ដូចនេះគ្រប់ការវាយតម្លៃឥណទាន គឺត្រូវបានធ្វើឡើងដោយឯករាជ្យ ។

ដោយសារបានធ្វើបច្ចុប្បន្នភាពលើគោលនយោបាយរួចរាល់ ដូច្នេះគ្រប់កម្ចីរបស់យើងត្រូវបានត្រួតពិនិត្យតាមដាន និងរាយការណ៍ជាប្រចាំ។ សញ្ញាបឋមដែលកើតមានឡើងលើកម្ចីដែលមានបញ្ហា ត្រូវបានកំណត់យកមកវិភាគ និងជជែកពិភាក្សាជាមួយអ្នកដែលពាក់ពន្ធ័ ដើម្បីរកដំណោះស្រាយឆ្លើយតបទៅតាមស្ថានភាពនីមួយៗ បើចាំបាច់ ។ ហើយនេះគឺជាមូលហេតុចម្បង ដែលធ្វើអោយយើងអាចគ្រប់គ្រងកម្ចីដែលមិនដំណើរការបានលទ្ធផលល្អ ក្នុងស្ថានភាពកូវីដ 19 ឆ្នាំ 2020 ។

ជាលទ្ធផល អត្រាផលបត្រឥណទានដែលមិនដំណើរការបានកើនឡើងបន្តិចបន្តួចពី 2.17% ក្នុងឆ្នាំ 2019 ទៅ នៅចុងឆ្នាំ 3.03% នៅចុងឆ្នាំ 2020 ក្នុងខណៈនោះដែរ បំណុលដែលបានបាត់បង់ បានប្រមូលមកវិញចំនួន 41.54% នៃបំណុលដែលបានបាត់បង់សរុប គិតត្រឹមខែធ្នូ ឆ្នាំ 2020 ។





ឃុន ប៉ោង និងគ្រួសារ ក្នុងផ្ទះជួលរបស់ពួកគាត់



"អរគុណសម្រាប់កម្ចីរយៈពេលវែងរបស់ ហ្វីស ហ្វាយនែន ដែលអាចអោយខ្ញុំ មានលទ្ធភាពបង់ប្រចាំខែបាន និងសល់ ប្រាក់ដើម្បីចិញ្ចឹមកូន និងបានបញ្ជូន ពួកគេទៅសាលារៀន"

នៅក្នុងឆ្នាំ 2017 ឃុន ប៉ោង និងប្រពន្ធឈ្មោះ រស់ គឹមសៀន ព្រមជាមួយកូនតូចពីរនាក់ទៀតបានចាកចេញពីស្រុកកំណើតនៅក្នុងស្រុកពួក ខេត្តសៀមរាប ដើម្បីមករស់នៅក្នុងក្រុងប៉ោយប៉ែត ។ ពួកគេបានរស់នៅក្នុងបន្ទប់ជួលដ៏តូចមួយ ។

ប៉ោង និងភរិយាមិនបានគិតថានឹងត្រលប់ទៅកាន់ស្រុកកំណើតវិញនោះទេ ។ ពួកគេស្រម៉ៃចង់បានផ្ទះមួយដើម្បីរស់នៅក្នុងជាយក្រុងប៉ោយប៉ែតនេះ ។ ពួកគាត់បានសម្រេចជំហ៊ានដំបូងក្នុងក្តីស្រម៉ៃបន្ទាប់ពីបានជួប ហ្វីស ហ្វាយនែន។

ឃុន ប៉ោង រកចំណូលបាន 230 ដុល្លារក្នុង មួយខែ ដោយគាត់ធ្វើសន្តិសុខយាមសណ្ឋាគារនៅពេលយប់ និងរត់ម៉ូតូឌុបនៅពេលថ្ងៃ ។ ចំណែកឯប្រពន្ធរបស់គាត់រកចំណូលបាន 240 ដុល្លារ ក្នុងមួយខែក្នុងតួនាទីជាអ្នករៀបចំបន្ទប់នៅសណ្ឋាគារតែមួយដែល ឃុន ប៉ោង ធ្វើការ ។ សម្រាប់ចំណូលសរុបប្រមាណ 470 ដុល្លារក្នុងមួយខែ វាមិនមែនជាការងាយនោះទេ ក្នុងការសន្សំប្រាក់អោយបានគ្រប់ដើម្បីទិញអចលនទ្រព្យ ដូចជាដី ឬផ្ទះជាដើម ។ នៅក្នុងឆ្នាំ 2019 ម្ចាស់គម្រោងអភិវឌ្ឍអចលនទ្រព្យដែលជាដៃគូរបស់ ហ្វីស ហ្វាយនែន បានណែនាំ ប៉ោង អោយមកស្នើកម្ចីពី ហ្វីស ហ្វាយនែន ដើម្បីទិញដីលំនៅដ្ឋាននៅផ្នែកឥសាន្តនៃក្រុងប៉ោយប៉ែត្រ ។ ជាមួយចំនូលដែលមានប្រចាំខែ ប៉ោង បានស្នើកម្ចីទំហំ 7,000 ដុល្លារ ជាមួយរយៈពេល 60 ខែ ។

ប៉ោង និងភរិយារបស់គាត់សប្បាយចិត្តយ៉ាងខ្លាំង ដែលពួកគាត់បានសម្រេចជំហ៊ានដំបូងនៃសុបិន្តចង់មានផ្ទះជាកម្មសិទ្ធិរបស់ខ្លួន ។ " អរគុណសម្រាប់កម្ចីរយៈពេលវែងរបស់ ហ្វីស ហ្វាយនែន ដែលអាចអោយខ្ញុំមានលទ្ធភាពបង់ប្រចាំខែបាន និងសល់ប្រាក់ដើម្បីចិញ្ចឹមកូន និងបានបញ្ជូនពួកគេទៅសាលារៀន " ប៉ោងនិយាយ ។ ពួកគាត់មានគម្រោងសាងសង់ផ្ទះនៅលើដីនេះ ក្នុងប៉ុន្មានឆ្នាំខាងមុខនេះ ធ្វើដូច្នេះពួកគាត់នឹងអាចចាកចេញពីផ្ទះជួលនេះបានហើយ ។

" ជាមួយប្រាក់សន្សំដែលយើងមាន យើងនឹងប្រើវាដើម្បីសាងសង់ផ្ទះក្នុងពេលឆាប់ៗខាងមុខនេះ ហើយប្រសិនបើមានការខ្វះខាតយើងប្រហែលជាត្រូវស្នើកម្ចីសាងសង់លំនៅដ្ឋានពី ហ្វីស ហ្វាយនែន " បន្ថែមទៀតក៏ថាបាន ប៉ោងបានបន្ថែម ។

# របាយការណ៍របស់សវនករឯករាជ្យ

( ដកស្រង់ពីរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 និងរបាយការណ៍របស់សវនករឯករាជ្យ )

ជូនចំពោះភាគទុនិករបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី

## មតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វីស ហ្វាយនែន ភីអិលស៊ី ហៅកាត់ថា (“ក្រុមហ៊ុន”) ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 របាយការណ៍លទ្ធផលលម្អិត របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍លំហូរទឹកប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់ ដែលរួមមានគោលនយោបាយគណនេយ្យសំខាន់ៗ ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗទៀត(ដែលហៅកាត់ថា “របាយការណ៍ហិរញ្ញវត្ថុ”) ។

ជាមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុជាសារវន្ត បានបង្ហាញនូវភាពត្រឹមត្រូវនៃស្ថានភាព ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរទឹកប្រាក់ របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដា របាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា (“ស.រ.ទ.ហ.អ.ក”) សម្រាប់សហគ្រាសធុនតូច និងមធ្យម ។

## មូលដ្ឋាននៃមតិសវនកម្ម

យើងខ្ញុំ បានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា ។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលស្របតាមស្តង់ដាទាំងនោះ ត្រូវបានរៀបរាប់បន្ថែមទៀតនៅក្នុងកថាខណ្ឌ ស្តីពីការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ ដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ ។ យើងខ្ញុំ មានភាពឯករាជ្យពីក្រុមហ៊ុន ដោយស្របទៅតាមតម្រូវការក្រមសីលធម៌វិជ្ជាជីវៈ ដែលពាក់ព័ន្ធនឹងសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុនៅក្នុង ព្រះរាជាណាចក្រកម្ពុជា ហើយយើងខ្ញុំបានបំពេញនូវទំនួលខុសត្រូវក្រមសីលធម៌វិជ្ជាជីវៈស្របតាមតម្រូវការរបស់ស្តង់ដាទាំងនោះ ។ យើងខ្ញុំជឿជាក់ថា ភស្តុតាងសវនកម្មដែលយើងខ្ញុំប្រមូលបានមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបសយើងខ្ញុំ ។

## ព័ត៌មានផ្សេងៗ

អ្នកគ្រប់គ្រង មានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ ។ ព័ត៌មានផ្សេងៗ ដែលបានទទួលត្រឹមកាលបរិច្ឆេទនៃ របាយការណ៍សវនកម្មនេះ គឺរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និង របាយការណ៍ប្រចាំឆ្នាំរបស់ក្រុមហ៊ុន ដែលរំពឹងថានឹងរួចរាល់ បន្ទាប់ពីកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ ។

មតិសវនកម្មរបស់យើងខ្ញុំ ទៅលើរបាយការណ៍ហិរញ្ញវត្ថុ មិនបានគ្របដណ្តប់លើព័ត៌មានផ្សេងៗទៀយ ហើយយើងខ្ញុំមិនធ្វើការផ្តល់នូវអំណះអំណាងណាមួយទៅលើព័ត៌មាននេះទេ ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំ លើរបាយការណ៍ហិរញ្ញវត្ថុ ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងៗ ហើយពិចារណាថាតើព័ត៌មានផ្សេងៗនោះ មានភាពមិនស្របគ្នាជាសារវន ជាមួយរបាយការណ៍ហិរញ្ញវត្ថុ ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត ។

ប្រសិនបើការអានព័ត៌មានផ្សេងៗ ដែលបានទទួលមុនកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មនេះ អាចឲ្យយើងខ្ញុំ សន្និដ្ឋានថា មានកំហុសឆ្គងជាសារវន្តកើតឡើងលើព័ត៌មានផ្សេងៗ នេះ យើងខ្ញុំត្រូវរាយការណ៍ទៅតាមស្ថានភាពជាក់ស្តែង ។ យើងខ្ញុំពុំមានអ្វីដែលត្រូវរាយការណ៍ពាក់ព័ន្ធនឹងព័ត៌មានផ្សេងៗ នេះទេ ។

## ការទទួលខុសត្រូវលើរបាយការណ៍ហិរញ្ញវត្ថុរបស់អ្នកគ្រប់គ្រង និងអ្នកទទួលខុសត្រូវលើអភិបាលកិច្ច

អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការរៀបចំ និងការបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម ហើយនិងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលអ្នកគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឲ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង ។

នៅក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ អ្នកគ្រប់គ្រងមានភារៈទទួលខុសត្រូវលើការវាយតម្លៃនូវលទ្ធភាពរបស់ក្រុមហ៊ុន ក្នុងការបន្តនិរន្តរភាពអាជីវកម្ម ទទួលខុសត្រូវលើការលាតត្រដាងព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហា ទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែអ្នកគ្រប់គ្រងមានបំណងចង់ជម្រះបញ្ជី ផ្អាកដំណើរការក្រុមហ៊ុន ឬគ្មានជម្រើសសមរម្យដទៃទៀតក្រៅពីធ្វើ បែបនេះ ។

អ្នកទទួលខុសត្រូវលើអភិបាលកិច្ច មានភារៈទទួលខុសត្រូវក្នុងការ

ត្រួតពិនិត្យដំណើរការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មរបាយការណ៍ហិរញ្ញវត្ថុ

គោលដៅរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថា របាយការណ៍ហិរញ្ញវត្ថុទាំងមូលមិនមានការ បង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍សវនកម្មដែលរួមបញ្ចូល ទាំងមតិសវនកម្មរបស់យើងខ្ញុំ ។ អំណះអំណាងសមហេតុផល គឺជាអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែវាមិនអាចធានាថា គ្រប់ពេលនៃការធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជាអាច រកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើង ដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានចាត់ទុកថាជាសារវន្ត នៅពេលដែលការក្លែងបន្លំ ឬកំហុសឆ្គងតែមួយ ឬក៏រួមបញ្ចូលគ្នា មានផលប៉ះពាល់ដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ ដោយយោងលើរបាយការណ៍ហិរញ្ញវត្ថុនេះ ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមទៅតាមស្តង់ដាសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបទៅដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈធាតុនិយមក្នុងអំឡុងពេលសវនកម្ម ។ យើងខ្ញុំក៏៖

- ធ្វើការកំណត់ និងវាយតម្លៃនូវហានិភ័យនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងទទួលខុសត្រូវលើការរៀបចំ និងការអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងប្រមូលនូវភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្របសម្រាប់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលកើតឡើង ដោយសារតែការក្លែងបន្លំមានលក្ខណៈខ្ពស់ជាងការបង្ហាញខុសកើតឡើងពីកំហុសឆ្គង ដោយសារតែការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការលួចបន្លំ ការលុបចោលដោយចេតនា ការបកស្រាយមិនពិត ឬមិនអនុវត្តតាមនីតិវិធីគ្រប់គ្រងផ្ទៃក្នុង ។
- ទទួលបាននូវការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្ម ក្នុងគោលបំណងដើម្បីរៀបចំនូវនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិលើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ ។
- ធ្វើការវាយតម្លៃលើភាពសមស្រប នៃគោលនយោបាយគណនេយ្យដែលក្រុមហ៊ុនបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យសំខាន់ៗព្រមទាំងការលាតត្រដាងព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយអ្នកគ្រប់គ្រង ។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យរបស់អ្នកគ្រប់គ្រង ហើយដោយផ្អែកទៅលើភស្តុតាងសវនកម្មដែលទទួលបាន ធ្វើការសន្និដ្ឋានថាតើភាពមិនច្បាស់លាស់ សារវន្តពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឲ្យមានមន្ទិលជាសារវន្ត លើលទ្ធភាពរបស់ក្រុមហ៊ុនដើម្បីបន្តនិរន្តរភាពអាជីវកម្ម ។ ប្រសិនបើយើងខ្ញុំ ធ្វើការសន្និដ្ឋានថាមានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍របស់យើងខ្ញុំ ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា ។ ការសន្និដ្ឋាន របស់យើងខ្ញុំ គឺផ្អែកតាមភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទនៃរបាយការណ៍សវនកម្មរបស់យើងខ្ញុំ ។ យ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចធ្វើឲ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាព នៃអាជីវកម្ម ។
- ធ្វើការវាយតម្លៃលើការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុទាំងមូល ដែលរួមបញ្ចូលទាំងការលាតត្រដាងព័ត៌មាន និងវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ពាក់ព័ន្ធក្នុងអត្ថន័យ ដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ ។

យើងខ្ញុំ ផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ច ស្តីពីបញ្ហាផ្សេងទៀត វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀតដែលមានរួមបញ្ចូលទាំងចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម ។

តំណាងក្រុមហ៊ុន **ខេភីអឹមជី ខេមបូឌា ចំកាត់**




**តាំង យុកហួច**

*Partner*

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ

នាថ្ងៃទី31 ខែធ្នូ ឆ្នាំ 2020

| | 2020<br>ដុល្លារអាមេរិក | 2019<br>ដុល្លារអាមេរិក | 2020<br>ពាន់រៀល | 2019<br>ពាន់រៀល |
|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | |
| សាច់ប្រាក់ និងសាច់ប្រាក់ | | | | |
| សមមូល | 2,317,780 | 1,733,737 | 9,375,420 | 7,064,978 |
| ប្រាក់តម្កល់តាមច្បាប់ | 180,102 | 180,102 | 728,513 | 733,916 |
| ឥណទានផ្តល់ដល់អតិថិជន - សុទ្ធ | 22,934,499 | 24,746,731 | 92,770,048 | 100,842,929 |
| ទ្រព្យសកម្មផ្សេងៗ | 318,811 | 580,220 | 1,289,590 | 2,364,397 |
| ទ្រព្យ និងបរិក្ខារ | 129,811 | 193,479 | 525,085 | 788,427 |
| ទ្រព្យសកម្មអរូបី | 73,265 | 100,643 | 296,357 | 410,120 |
| ពន្ធពន្យារជាទ្រព្យសកម្ម - សុទ្ធ | 29,623 | 29,623 | 119,825 | 120,715 |
| **ទ្រព្យសកម្មសរុប** | 25,983,891 | 27,564,535 | 105,104,838 | 112,325,482 |
| | | | | |
| **បំណុល និងមូលធន** | | | | |
| **បំណុល** | | | | |
| ប្រាក់កម្ចី | 18,139,154 | 19,449,810 | 73,372,878 | 79,257,976 |
| បំណុលផ្សេងៗ | 602,425 | 948,917 | 2,436,810 | 3,866,839 |
| អត្ថប្រយោជន៍និយោជិត | 141,440 | 140,187 | 572,123 | 571,262 |
| បំណុលពន្ធលើប្រាក់ចំណេញ | | | | |
| ប្រចាំឆ្នាំ | 21,667 | 43,485 | 87,643 | 177,201 |
| **បំណុលសរុប** | 18,904,686 | 20,582,399 | 76,469,454 | 83,873,278 |
| | | | | |
| **មូលធន** | | | | |
| ដើមទុន | 3,602,033 | 3,602,033 | 14,408,132 | 14,408,132 |
| បុព្វលាភដើមទុន | 879,482 | 879,482 | 3,517,928 | 3,517,928 |
| ទុនបម្រុងតាមបទប្បញ្ញត្តិ | 340,012 | 316,505 | 1,373,672 | 1,277,834 |
| ប្រាក់ចំណេញរក្សាទុក | 2,257,678 | 2,184,116 | 9,119,776 | 8,819,863 |
| ទុនបម្រុងលើការប្តូររូបិយប័ណ្ណ | - | - | 215,876 | 428,447 |
| **មូលធនសរុប** | 7,079,205 | 6,982,136 | 28,635,384 | 28,452,204 |
| **បំណុល និងមូលធនសរុប** | 25,983,891 | 27,564,535 | 105,104,838 | 112,325,482 |

# របាយការណ៍លទ្ធផលលម្អិត

នាថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2020

| | 2020<br>ដុល្លារអាមេរិក | 2019<br>ដុល្លារអាមេរិក | 2020<br>ពាន់រៀល | 2019<br>ពាន់រៀល |
|---|---|---|---|---|
| **ចំណូលពីប្រតិបត្តិការ** | | | | |
| ចំណូលពីការប្រាក់ | 3,494,247 | 3,466,588 | 14,246,045 | 14,046,615 |
| ចំណាយលើការប្រាក់ | ( 1,692,758 ) | ( 1,655,773 ) | ( 6,901,374 ) | ( 6,709,192 ) |
| ចំណូលពីការប្រាក់សុទ្ធ | 1,801,489 | 1,810,815 | 7,344,671 | 7,337,423 |
| ចំណូលកម្រៃ និងជើងសា - សុទ្ធ | 381,713 | 556,202 | 1,556,244 | 2,253,731 |
| ចំណូលផ្សេងៗ | 92,367 | 83,288 | 376,580 | 337,483 |
| **ចំណូលពីប្រតិបត្តិការសរុប** | 2,275,569 | 2,450,305 | 9,277,495 | 9,928,637 |
| ការខាតបង់លើឱនភាពនៃតម្លៃ | | | | |
| ទ្រព្យសកម្មសុទ្ធ | ( 201,060 ) | ( 342,503 ) | ( 819,722 ) | ( 1,387,822 ) |
| ចំណាយលើបុគ្គលិក | ( 1,129,418 ) | ( 1,190,297 ) | ( 4,604,637 ) | ( 4,823,083 ) |
| រំលស់ | ( 114,941 ) | ( 126,677 ) | ( 468,614 ) | ( 513,295 ) |
| ចំណាយលើប្រតិបត្តិការផ្សេងៗ | ( 675,238 ) | ( 614,322 ) | ( 2,752,945 ) | ( 2,489,233 ) |
| **ចំណាយលើប្រតិបត្តិការសរុប** | ( 2,120,657 ) | ( 2,273,799 ) | ( 8,645,918 ) | ( 9,213,433 ) |
| ប្រាក់ចំណេញមុនបង់ពន្ធ | 154,912 | 176,506 | 631,577 | 715,204 |
| ចំណាយពន្ធលើប្រាក់ចំណេញ | ( 57,843 ) | ( 78,650 ) | ( 235,826 ) | ( 318,690 ) |
| **ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ** | 97,069 | 97,856 | 395,751 | 396,514 |
| **លទ្ធផលលម្អិតផ្សេងៗ** | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | ( 212,571 ) | 394,653 |
| **លទ្ធផលលម្អិតសរុបសម្រាប់ការិយបរិច្ឆេទ** | 97,069 | 97,856 | 183,180 | 791,167 |

# របាយការណ៍ស្តីពីបម្រែបម្រួលមូលធន

នាថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2020

| | ដើមទុន | | បុព្វលាភដើមទុន | | ទុនបម្រុងតាមបទប្បញ្ញត្តិ | | ប្រាក់ចំណេញរក្សាទុក | | ទុនបម្រុងលើការប្តូររូបិយប័ណ្ណ | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2019 | 3,602,033 | 14,408,132 | 879,482 | 3,517,928 | 303,766 | 1,226,216 | 2,098,999 | 8,474,967 | - | 33,794 | 6,884,280 | 27,661,037 |
| **ប្រតិបត្តិការទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន** | | | | | | | | | | | | |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | 12,739 | 51,618 | ( 12,739 ) | ( 51,618 ) | - | - | - | - |
| **លទ្ធផលលម្អិតសរុប** | | | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | 97,856 | 396,514 | - | - | 97,856 | 396,514 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | 394,653 | - | 394,653 |
| | - | - | - | - | - | - | 97,856 | 396,514 | - | 394,653 | 97,856 | 741,167 |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2019 | 3,602,033 | 14,408,132 | 879,482 | 3,517,928 | 316,505 | 1,277,834 | 2,184,116 | 8,819,863 | - | 428,447 | 6,982,136 | 28,452,204 |
| នាថ្ងៃទី 1 ខែ មករា ឆ្នាំ 2020 | 3,602,033 | 14,408,132 | 879,482 | 3,517,928 | 316,505 | 1,277,834 | 2,184,116 | 8,819,863 | - | 428,447 | 6,982,136 | 28,452,204 |
| **ប្រតិបត្តិការទទួលស្គាល់ដោយផ្ទាល់នៅក្នុងមូលធន** | | | | | | | | | | | | |
| ការផ្ទេរទៅទុនបម្រុងតាមបទប្បញ្ញត្តិ | - | - | - | - | 23,507 | 95,838 | ( 23,507 ) | ( 95,838 ) | - | - | - | - |
| លទ្ធផលលម្អិតសរុប | | | | | | | | | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | - | - | - | - | - | - | 97,069 | 395,751 | - | - | 97,069 | 395,751 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | - | - | - | - | - | - | - | ( 212,571 ) | - | ( 212,571 ) |
| | - | - | - | - | - | - | 97,069 | 395,751 | - | ( 212,571 ) | 97,069 | 183,180 |
| នាថ្ងៃទី 31 ខែ ធ្នូ ឆ្នាំ 2020 | 3,602,033 | 14,408,132 | 879,482 | 3,517,928 | 340,012 | 1,373,672 | 2,257,678 | 9,119,776 | - | 215,876 | 7,079,205 | 28,635,384 |

# របាយការណ៍លំហូរទឹកប្រាក់

នាថ្ងៃទី 31 ខែធ្នូ ឆ្នាំ 2020

| | 2020 ដុល្លារអាមេរិក | 2019 ដុល្លារអាមេរិក | 2020 ពាន់រៀល | 2019 ពាន់រៀល |
|---|---|---|---|---|
| **លំហូរទឹកប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | 97,069 | 97,856 | 395,751 | 396,514 |
| *និយ័តភាពលើ៖* | | | | |
| ចំណាយពន្ធលើប្រាក់ចំណេញ | 57,843 | 78,650 | 235,826 | 318,690 |
| ចំណូលពីការប្រាក់សុទ្ធ | (1,801,489) | (1,810,815) | (7,344,671) | (7,337,423) |
| សំវិធានធនលើអត្ថប្រយោជន៍និយោជិត | 10,965 | 40,594 | 44,704 | 164,487 |
| រំលស់ | 114,941 | 126,677 | 468,614 | 513,295 |
| ការលុបចោលទ្រព្យ និងបរិក្ខារ | 2,946 | 352 | 12,011 | 1,426 |
| ការខាតបង់លើឱនភាពនៃតម្លៃនៃឧបករណ៍ហិរញ្ញវត្ថុសុទ្ធ | 201,060 | 342,503 | 819,722 | 1,387,822 |
| | (1,316,665) | (1,124,183) | (5,368,043) | (4,555,189) |
| *បម្រែបម្រួលនូវ៖* | | | | |
| ឥណទានផ្តល់ដល់អតិថិជន | 1,611,172 | (4,856,112) | 6,568,748 | (19,676,966) |
| ទ្រព្យសកម្មផ្សេងៗ | 261,409 | (223,610) | 1,065,764 | (906,068) |
| បំណុលផ្សេងៗ | (346,492) | 673,084 | (1,412,648) | 2,727,336 |
| សាច់ប្រាក់ប្រើប្រាស់ក្នុងសកម្មភាពប្រតិបត្តិការ | 209,424 | (5,530,821) | 853,821 | (22,410,887) |
| ការប្រាក់ដែលបានទទួល | 3,494,247 | 3,451,065 | 14,246,045 | 13,983,715 |
| ការប្រាក់បានបង់ | (1,774,209) | (1,639,702) | (7,233,450) | (6,644,073) |
| ការទូទាត់អត្ថប្រយោជន៍និយោជិត | (9,712) | (68,832) | (39,596) | (278,907) |
| ពន្ធលើប្រាក់ចំណេញបានបង់ | (79,661) | (71,517) | (324,778) | (289,787) |
| **សាច់ប្រាក់សុទ្ធទទួលបានពី/(ប្រើប្រាស់) ក្នុងសកម្មភាពប្រតិបត្តិការ** | 1,840,089 | (3,859,807) | 7,502,042 | (15,639,939) |
| **លំហូរទឹកប្រាក់ពីសកម្មភាពវិនិយោគ** | | | | |
| ការទិញទ្រព្យ និងបរិក្ខារ | (20,103) | (95,681) | (81,960) | (387,699) |
| ការទិញទ្រព្យសកម្មអរូបី | (6,738) | (17,820) | (27,471) | (72,207) |
| ការដកប្រាក់បញ្ញើមានលក្ខខណ្ឌ | - | 168,899 | - | 684,379 |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ទទួលបានពីសកម្មភាពវិនិយោគ** | (26,841) | 55,398 | (109,431) | 224,473 |
| **លំហូរទឹកប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | |
| ការទូទាត់សងប្រាក់កម្ចី | (5,355,129) | (6,650,755) | (21,832,861) | (26,948,859) |
| សាច់ប្រាក់ទទួលបានពីប្រាក់កម្ចី | 4,125,924 | 10,994,751 | 16,821,392 | 44,550,731 |
| **សាច់ប្រាក់សុទ្ធ(ប្រើប្រាស់ក្នុង)/ទទួលបានពីសកម្មភាពហិរញ្ញប្បទាន** | (1,229,205) | 4,343,996 | (5,011,469) | 17,601,872 |
| **ការកើនឡើងសុទ្ធនៃសាច់ប្រាក់ និងសាច់ប្រាក់សមមូល** | 584,043 | 539,587 | 2,381,142 | 2,186,406 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី 1 ខែ មករា** | 1,733,737 | 1,194,150 | 7,064,978 | 4,798,095 |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | - | (70,700) | 80,477 |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលនាថ្ងៃទី 31 ខែ ធ្នូ** | 2,317,780 | 1,733,737 | 9,375,420 | 7,064,978 |





> អរគុណសម្រាប់លក្ខខណ្ឌងាយស្រួលក្នុងការស្នើកម្ចីបន្ថែម និងកម្ចីរយៈពេលវែងរបស់ ហ្វីស ហ្វាយនែន ដែលអាចអោយខ្ញុំសម្រេចបំណងប្រាថ្នាក្នុងការមានផ្ទះ និងមានអាជីវកម្មជារបស់ផ្ទាល់ខ្លួន

កាលពី 10 ឆ្នាំ មុន ចក់ ធឿន បានចាកចេញពីខេត្តកំពង់ចាម មករស់នៅជាមួយបងប្រុសនៅក្នុងខេត្តបន្ទាយមានជ័យ ។ គាត់បានធ្វើការអោយបងប្រុសរបស់គាត់ ក្នុងមុខងារជាជាងទង ។

នៅក្នុងឆ្នាំ 2016 គាត់បានរៀបការជាមួយប្រពន្ធរបស់គាត់ ឈ្មោះ សុខ ដានី ដែលជាពេទ្យឆ្មបបម្រើការនៅមណ្ឌលសុខភាពរដ្ឋ ។ មួយឆ្នាំក្រោយមក ភរិយារបស់គាត់សម្រាលបានកូនប្រុសម្នាក់គួរអោយស្រឡាញ់ ។ វាជាពេលវេលាមួយដែលគាត់បានសន្យាថានឹងត្រូវមានផ្ទះជាកម្មសិទ្ធិផ្ទាល់ខ្លួន ដើម្បីរស់នៅដោយពឹងខ្លួនឯងជាមួយក្រុមគ្រួសារអោយបានកាន់តែឆាប់កាន់តែល្អ ។ ពួកគាត់បានចាប់ផ្ដើមស្វែងរកផ្ទះដែលអាចប្រើប្រាស់បានទាំងសម្រាប់រស់នៅ និងប្រកបរបរធ្វើគ្រឿងអលង្ការ ដែលជំនាញនេះគាត់ទទួលបានកាលពីគាត់ធ្វើការអោយបងប្រុសរបស់គាត់ ។

នៅក្នុងឆ្នាំ 2018 ម្ចាស់បុរីបាននាំ ធឿន អោយស្នើកម្ចីពី ហ្វីស ហ្វាយនែន ។ ជាមួយចំណូលប្រចាំខែប្រមាណ 1,350 ដុល្លារក្នុង មួយខែ ធឿន និងភរិយាសម្រេចចិត្តស្នើកម្ចីចំនួន 30,000 ដុល្លារ សម្រាប់រយៈពេល 120 ខែ ដោយក្នុងនោះគាត់យកទៅទិញផ្ទះចំនួន 25,000 ដុល្លារ ចំណែក 5,000 ដុល្លារទៀត គាត់បានយកទៅទិញសម្ភារវត្ថុធាតុដើម និងជីសកូនឈ្នួលចំនួន 2 នាក់ដើម្បីចាប់ផ្ដើមអាជីវកម្មជាងទងរបស់គាត់ ។ គាត់ប្រើផ្ទះគាត់មួយចំណែកធ្វើជារោងជាង ។

ធឿន មានការពេញចិត្តលើលក្ខខណ្ឌកម្ចីបន្ថែម និងរយៈពេលវែងដែលផ្ដល់ដោយ ហ្វីស ហ្វាយនែន ដែលលក្ខខណ្ឌនេះអាចអោយគាត់បើកអាជីវកម្ម និងមានលទ្ធភាពបង់ប្រាក់ប្រចាំខែបាន ។ “ អរគុណសម្រាប់លក្ខខណ្ឌងាយស្រួលក្នុងការស្នើកម្ចីបន្ថែម និងកម្ចីរយៈពេលវែងរបស់ ហ្វីស ហ្វាយនែន ដែលអាចអោយខ្ញុំសម្រេចបំណងប្រាថ្នាក្នុងការមានផ្ទះ និងមានអាជីវកម្មជារបស់ផ្ទាល់ខ្លួន ដែលខ្ញុំបានប៉ងជាយូរមកហើយ ” នេះជាប្រសាសន៍របស់ ធឿន ។

# ក្រុមប្រឹក្សាភិបាល និងថ្នាក់ដឹកនាំ







## HANCO HALBERTSMA

### ប្រធានក្រុមប្រឹក្សាភិបាល

លោក Hanco Halbertsma គឺជាទីប្រឹក្សាផ្នែកយុទ្ធសាស្រ្តសម្រាប់ធនាគារ ស្ថាប័នហិរញ្ញវត្ថុ និងស្ថាប័នមីក្រូហិរញ្ញវត្ថុក្នុងប្រទេសកំពុងអភិវឌ្ឍន៍និងសម្រាប់អ្នកដែលចង់វិនិយោគលើស្ថាប័នហិរញ្ញវត្ថុ ។ ក្នុងរយៈពេលជាង20ឆ្នាំកន្លងទៅនេះ លោកបានធ្វើការក្នុងគម្រោងជាច្រើន ជាអ្នកជំនាញវិស័យហិរញ្ញវត្ថុ ដែលរួមមាន ផ្នែកមីក្រូហិរញ្ញវត្ថុ ផ្នែកធនាគារសម្រាប់អាជីវកម្ម ផ្នែកធនាគារសម្រាប់បុគ្គល ផ្នែកធនាគារសម្រាប់សហគ្រាសខ្នាតតូច ផ្នែកគ្រប់គ្រងហានិភ័យឥណទាន ផ្នែកអភិបាលកិច្ចសាជីវកម្ម និងផ្នែកហិរញ្ញប្បទាន ។

ក្នុងតួនាទីជាប្រធានក្រុមប្រឹក្សាភិបាលរបស់ហ្វីសហ្វាយនែន លោក Hanco ផ្តល់ការគាំទ្រផ្នែកយុទ្ធសាស្រ្ត ផ្នែកស្វែងរកមូលនិធិ ផ្នែកគ្រប់គ្រងហានិភ័យឥណទាន ផ្នែកហិរញ្ញវត្ថុ និងផ្នែកកសាងសមត្ថភាពបុគ្គលិក។ មុនពេលចាប់ផ្តើមជាមួយហ្វីសហ្វាយនែន លោកមានបទពិសោធន៍ក្នុងប្រទេសកម្ពុជាចំនួន៦ឆ្នាំមកហើយ ក្នុងនាមជាអភិ-បាលនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ដែលជាគ្រឹះ-ស្ថានមីក្រូហិរញ្ញវត្ថុធំជាងគេក្នុងប្រទេសកម្ពុជា ។ សព្វថ្ងៃលោកក៏ជាអភិបាលស្ថាប័ន Caspian Impact Investments Private Limited (CII) ដែលជាស្ថាប័នហិរញ្ញវត្ថុសម្រាប់សហគ្រាសខ្នាតតូចក្នុងប្រទេសឥណ្ឌាដែលមានការរីកចម្រើនដ៏គួរឲ្យកត់សម្គាល់ ។

លោក Hanco គឺជាស្ថាបនិកក្រុមហ៊ុន Priority Project Limited (PPL) ដែលជាក្រុមហ៊ុនជំនាញក្នុងការប្រឹក្សាយោបល់ផ្នែកយុទ្ធសាស្រ្ត និង ផ្នែកប្រតិបត្តិការសម្រាប់ស្ថាប័នហិរញ្ញវត្ថុ និង វិនិយោគិនក្នុងតំបន់អាស៊ី ។ ក្រុមហ៊ុននេះត្រូវបានបង្កើតឡើង បន្ទាប់ពីលោកបានធ្វើការក្នុងក្រុមហ៊ុន ING Group អស់រយៈពេល១៦ឆ្នាំ ដែលក្នុងនោះរយៈពេល៨ឆ្នាំ គឺលោកបានធ្វើក្នុងក្រុមហ៊ុន ING-IGA ដែលជាក្រុមហ៊ុនពិគ្រោះយោបល់ក្នុងបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ។

លោក Hanco បានបញ្ចប់ការសិក្សា ថ្នាក់អនុបណ្ឌិតជំនាញរដ្ឋបាលអាជីវកម្ម ហើយគាត់កំពុងធ្វើការក្នុងទីក្រុងហុងកុង។

## TALMAGE PAYNE

### អភិបាល

#### តំណាងម្ចាស់ភាគហ៊ុន ហ្វីស ហូម ភីអិលស៊ី

លោក Talmage Payne ជាសហគ្រិន និងអ្នកមានគំនិតច្នៃប្រឌិតមួយរូប ហើយសព្វថ្ងៃជាប្រធាននៃអង្គការសេចក្តីសង្ឃឹមពិភពលោកអន្តរជាតិប្រចាំនៅកម្ពុជា។ គាត់គឺជាស្ថាបនិក ហ្វីស ហ្វាយនែន និងអាជីវកម្មសង្គមជាច្រើនទៀត។ គាត់បានចំណាយពេលស្ទើរមួយជីវិតរបស់គាត់រស់ នៅទ្វីបអាស៊ី ដើម្បីធ្វើការទាំងក្នុងស្ថាប័នរកប្រាក់ចំណេញ និងស្ថាប័នមិនរកប្រាក់ចំណេញ ដែលផ្តល់ភាពវិជ្ជមានដល់សង្គម ។ គាត់ធ្លាប់ជានាយកប្រតិបត្តិនៃអង្គការ Hagar International (ការការពារ និង ការធ្វើឲ្យប្រសើរឡើងដល់អ្នកដែលរួចផុតពីការជួញដូរមនុស្ស) និងបានជួយបង្កើត Hagar ចំនួន ៩ប្រទេសដោយប្រើម៉ូដែល មានទាំងការរកប្រាក់ចំណេញ និងមិនរកប្រាក់ចំណេញ ។ លោកធ្លាប់ជានាយកអង្គការទស្សនៈពិភពលោកកម្ពុជា និងជាប្រធានស្ថាបនិក វីសិនហ្វាន់កម្ពុជា។ រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់ការងារមនុស្សធម៌របស់លោកជាច្រើនលើកតាមរយៈការបំពាក់មេដាយ ថ្នាក់មនុស្សជាតិពីរដង និងងារសហមេត្រី។ លោក បានសិក្សាមុខវិជ្ជាអភិវឌ្ឍន៍សេដ្ឋកិច្ចនៅសាកលវិទ្យាល័យ Wheaton College។

## NICHOLAS LAZOS

### អភិបាល

#### តំណាងម្ចាស់ភាគហ៊ុន Insitor Fund

លោក Nicholas Lazos គឺជាសហស្ថាបនិក និង ជានាយកនៃក្រុមហ៊ុន Insitor Impact Asia Fund លោក Nicholas បានធ្វើការនៅក្នុងតំបន់អាស៊ីខាងត្បូង និង អាស៊ីអាគ្នេយ៍អស់រយៈពេល10ឆ្នាំមកហើយ ក្នុងការជួយសហគ្រាសផ្នែកសង្គមក្នុងដំណាក់កាលចាប់ផ្តើមរបស់គេ ។ លោក Nicholas ទទួលខុសត្រូវលើវិនិយោគទុនធំៗ និង មានតួនាទីជាអភិបាលនៅក្នុងក្រុមហ៊ុនដែល Insitor បានវិនិយោគ ។ មុននឹងចូលបម្រើការនៅ Insitor លោក Nicholas គឺជាប្រធានចាត់ការទូទៅរបស់ក្រុមហ៊ុន ដែលផ្តល់ដំណោះស្រាយខាងគេហដ្ឋានដល់អ្នកដែលមានចំណូលទាបមុនគេបង្អស់នៅកម្ពុជា ។ លោកបានរៀបចំចាត់ចែងតាំងពីដំបូង និងអភិវឌ្ឍរហូតមានប្រតិ-បត្តិការពេញលេញ ។ គាត់ទទួលបានសញ្ញាប័ត្រពីរគឺផ្នែកគណិតវិទ្យានៅក្នុងកម្មវិធីវិទ្យាសាស្រ្តសង្គមពីសាកលវិទ្យាល័យ Northwestern University ។



## ONG TEONG HOON

### អភិបាល

តំណាងម្ចាស់ភាគហ៊ុន Phillip Capital

លោក Ong Teong Hoon មានបទពិសោធន៍ជាង ៣០ឆ្នាំ ក្នុងវិស័យធនាគារនៅអាស៊ុ និងបទ-ពិសោធន៍ ប៉ុន្មានឆ្នាំចុងក្រោយក្នុងវិស័យមីក្រូ-ហិរញ្ញវត្ថុ។ លោក Teong Hoon គឺជានាយកប្រតិបត្តិជាន់ខ្ពស់ប្រចាំក្រុមហ៊ុន Phillip Capital ដែលជាក្រុមហ៊ុននាំមុខមួយនៅក្នុងអាស៊ុ ហើយបច្ចុប្បន្នលោកជាអភិបាល និងជាតំណាងម្ចាស់ភាគហ៊ុននៅធនាគារ Phillip និងជាអភិបាលរបស់ក្រុមហ៊ុនធានារ៉ាប់រង Phillip ក្នុងប្រទេសកម្ពុជា ។
លោកជាប្រធានក្រុមប្រឹក្សាភិបាលសាលា Methodist ក្នុងប្រទេសកម្ពុជា និងមានតួនាទីជាថ្នាក់ដឹកនាំកំពូលនៃកម្មវិធី Youth and Detention Rehabilitation Program ។ លោក Teong Hoon ក៏ជាសមាជិកស្ថាបនិកក្រុមប្រឹក្សាភិបាលរបស់ហ្វីស ហ្វាយនែន និងបានធ្វើដំណើរជាមួយយើងឆ្លងកាត់ទាំងភាពលំបាក ការរីកចម្រើនខ្លាំង និងជ័យជំនះ។ គាត់ក៏ជាសមាជិកនៃវិទ្យាស្ថានធនាគារក្នុងទីក្រុងឡុងដ៍ផងដែរ (The Chartered Institute of Bankers in London) ។



## FAY CHETNAKARNKUL

### អភិបាល

Norfund

អ្នកស្រី Fay Chetnakarnkul ជានាយិកាផ្នែកវិនិយោគនិងជាប្រធាននៃ Norfund ប្រចាំនៅអាស៊ុ ។ អ្នកស្រីមានតួនាទីក្នុងការគ្រប់គ្រង និងដឹកនាំផលបត្ររបស់ Norfund នៅអាស៊ុ។ មុនមកកាន់ Norfund អ្នកស្រីបានបម្រើការងារនៅសហប្រតិ-បត្តិការហិរញ្ញវត្ថុអន្តរជាតិនិងធនាគាពិភពលោក។
អ្នកស្រីក៏មានបទពិសោធន៍ក្នុងវិស័យអភិវឌ្ឍន៍ហិរញ្ញវត្ថុតាមបណ្តាប្រទេសនៅតំបន់អាស៊ុអាគ្នេយ៍ អាហ្វ្រិក អាមេរិកឡាទីន និងអឺរ៉ុបខាងកើត។
អ្នកស្រីបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យ Johns Hopkins ផ្នែកសិក្សាអន្តរជាតិជាន់ខ្ពស់។



## PAUL FREER

### អភិបាលឯករាជ្យ

លោក Paul Freer មានបទពិសោធន៍ក្នុងតំណែងជាន់ខ្ពស់ជាង ២០ឆ្នាំជាមួយធនាគារអន្តរជាតិ និងមានប្រវត្តិទទួលបានជោគជ័យក្នុងការគ្រប់គ្រងគម្រោង ការអប់រំ ជាមួយវិស័យអង្គការមិនរកប្រាក់ចំណេញក្នុងប្រទេសកម្ពុជា ។
លោក Paul បានចាប់ផ្តើមអាជីពធនាគារដំបូង ក្នុងប្រទេសអង់គ្លេស មុនពេលចំណាយពេល១៥ឆ្នាំទៀតធ្វើការក្នុងប្រទេសកម្ពុជា និងប្រទេសឡាវក្នុងមុខដំណែងអ្នកគ្រប់គ្រងជាន់ខ្ពស់ ក្នុងអង្គការទាំងរកប្រាក់ចំណេញ និងមិនរកប្រាក់ចំណេញ ។ លោក Paul ធ្លាប់ជានាយកប្រតិបត្តិធនាគារ Standard Charted Bank ក្នុងប្រទេសកម្ពុជា នាយកគ្រប់គ្រងធនាគារ Phongsavanh Bank ក្នុងប្រទេសឡាវ និងជានាយកផ្នែក Retail Banking នៃធនាគារ ANZ Royal Bank (Cambodia)។ គាត់ក៏បានរួមចំណែកក្នុងការបង្កើតធនាគារ MARUHAN Japan BANK ក្នុងប្រទេសកម្ពុជាដោយគាត់បានបំរើការជាអគ្គនាយករង និងជាអ្នកចាត់ការទូទៅ ។
លោក Paul គឺជាសមាជិកគណៈកម្មាធិការផ្នែកហិរ-ញ្ញវត្ថុ និងសម្ភារបរិក្ខាររបស់សាលា International School of Phnom Penh និងជាអ្នកប្រឹក្សាឯករាជ្យលើវិស័យធនាគារ និងមីក្រូហិរញ្ញវត្ថុជាមួយធនាគារពិភពលោក ក៏ដូចជាអង្គការដ៏ទៃទៀត។
លោក Paul ទទួលបានសញ្ញាបត្រអនុបណ្ឌិតគ្រប់គ្រងពាណិជ្ជកម្មពីសាកលវិទ្យាល័យ Southampton Business School របស់ប្រទេសអង់គ្លេស។

# ក្រុមប្រឹក្សាភិបាល



## JOSHUA MORRIS

### អ្នកអង្កេត

តំណាងម្ចាស់ភាគហ៊ុន CLDF

លោក Joshua Morris ជាដៃគូរស្ថាបនិក និងជានាយកគ្រប់គ្រងនៃ Emerging Markets Investments (EMI) ជាអាជីវកម្មផ្តល់ប្រឹក្សាវិនិយោគដែលមានមូលដ្ឋាននៅប្រទេសកម្ពុជា និងដែលគ្រប់គ្រងមូលនិធិ Cambodia-Laos Development Fund ។ មុនពេលបង្កើត EMI លោក Joshua បានចូលរួមយ៉ាងសកម្មក្នុងការអភិវឌ្ឍវិស័យឯកជន និងផ្តល់ប្រឹក្សាអាជីវកម្មនៅក្នុងអាស៊ីអាគ្នេយ៍ តាមរយៈតួនាទីរបស់លោកជាសហស្ថាបនិកក្រុមហ៊ុន Emerging Markets Consulting ដែលជាក្រុមហ៊ុនប្អូនរបស់ក្រុមហ៊ុន EMI ។

មុនពេលប្តូរមករស់នៅកម្ពុជា ក្នុងឆ្នាំ 2004 លោក Joshua មានការងារជាអ្នកគ្រប់គ្រងជាន់ខ្ពស់ផ្នែកទីផ្សារ និងអភិវឌ្ឍន៍សាជីវកម្មនៃក្រុមហ៊ុនបច្ចេកវិទ្យាដែលទើបចាប់ផ្តើម និង ជាក្រុមហ៊ុនពាណិជ្ជកម្មអេឡិចត្រូនិក ដែលចុះបញ្ជីទីផ្សារភាគហ៊ុនជាមួយ NASDQ ។

លោក Joshua ទទួលបានសញ្ញាបត្រអនុបណ្ឌិតពីសាកលវិទ្យាល័យ Harvard Business School ឆ្នាំ1998 និងសញ្ញាបត្របរិញ្ញាបត្រកិត្តិយសពី Harvard University ក្នុងឆ្នាំ1992 ។



## DAVID LITTLEJOHN

### អភិបាលឯករាជ្យ

ធ្លាប់បម្រើការងារផ្នែកលក់ក្នុងប្រទេសសិង្ហបុរី និងទីក្រុងបាងកក ជាង 20ឆ្នាំ លោក David Littlejohn ដែលមានកំណើតក្នុងប្រទេសញូហ្សេលែន បានមកប្រទេសកម្ពុជាកាលពី 6 ឆ្នាំមុន ដោយបានចូលបម្រើការងារជាប្រធានផ្នែកលក់ និងទីផ្សារឲ្យក្រុមហ៊ុន Comin Khmere ដែលជាក្រុមហ៊ុនឈានមុខ ក្នុងការផ្តល់ដំណោះស្រាយផ្នែកវិស្វកម្មក្នុងប្រទេសកម្ពុជា។ ក្រុមហ៊ុន Comin Khmere រៀបចំ អនុវត្ត និងថែទាំប្រព័ន្ធ ក្នុងវិស័យវិស្វកម្មអគ្គិសនី និងគ្រឿងយន្ត ម៉ាស៊ីនត្រជាក់ និងទូទឹកកក ថាមពលមិនកកើត និងថាមពលកកើតឡើងវិញ ការរៀបចំប្រព័ន្ធទឹក ការការពារអគ្គិភ័យ ហេដ្ឋារចនាសម្ព័ន្ធបណ្តាញ សន្តិសុខ និងស្វ័យប្រវត្តិកម្ម និងដំណោះស្រាយ ផ្នែកជណ្តើរយន្ត។

កម្ចីសាងសង់ ឬជួសជុលផ្ទះគឺជាផលិតផលសំខាន់មួយរបស់យើង ក្នុងការ ផ្តល់ដំណោះស្រាយហិរញ្ញវត្ថុ រយៈពេលវែងសម្រាប់អ្នកដែលចង់សង់ផ្ទះថ្មី នៅលើដីរបស់ខ្លួន ឬជួសជុលផ្ទះរបស់ខ្លួន។



# គណៈគ្រប់គ្រង







## ផុន សុថានី
### អគ្គនាយិកាប្រតិបត្តិ

អ្នកស្រី ផុន សុថានី បានចាប់ផ្តើមអាជីពជាមួយ អង្គការទស្សនៈពិភពលោក ជាសវនករផ្ទៃក្នុង នៅក្នុងឆ្នាំ 2002 ។ ចាប់តាំងពីពេលនោះមក លោកស្រី មានការរីកចម្រើនយ៉ាងលឿនជាមួយ តួនាទីជាច្រើន រួមមានការគ្រប់គ្រងការបង្កើតគម្រោង ការបង្កើតសំណើរ (Propsoal Develo pment) ការពិនិត្យការរីកចម្រើន និងការកសាងទំនាក់ទំនងជាមួយម្ចាស់ជំនួយ ។
នៅឆ្នាំ2007 លោកស្រី បានក្លាយជាប្រធានផ្នែកអភិវឌ្ឍន៍ពាណិជ្ជកម្មនៃ វីសិនហ្វាន់ កម្ពុជា ដែលលោកស្រីទទួលខុសត្រូវផ្នែករកមូលនិធិ ផ្នែកទីផ្សារ ផ្នែកទំនាក់ទំនង និងអភិវឌ្ឍន៍ផលិតផល ។ ឆ្នាំ2008 លោកស្រីផ្លាស់ទៅក្រុមហ៊ុន វីង ដែលនៅទីនោះ លោកស្រីបានបង្កើតផែនការយុទ្ធសាស្រ្ត និងគ្រប់គ្រងការលក់ រួមទាំងការលើកទឹកចិត្តនិងពង្រីកភ្នាក់ងារលក់ជាង 900 នាក់ ។ លោកស្រី សុថានី បានចូលបម្រើការជាមួយ ហ្វីស ហ្វាយនែន នៅឆ្នាំ 2011 ជានាយិកាផ្នែកហិរញ្ញវត្ថុ ហើយត្រូវបានតែងតាំងជាអគ្គនាយិកាប្រតិបត្តិ នៅខែសីហា ឆ្នាំ 2014 ។
លោកស្រី សុថានី បានទទួលបរិញ្ញាបត្រគ្រប់គ្រងផ្នែកគណនេយ្យ និងបានបន្តអនុបណ្ឌិតអភិវឌ្ឍអង្គ-ភាពក្នុងការគ្រប់គ្រងកម្ចីខ្នាតតូច ។

## ហេង សក្តា
### ប្រធាននាយដ្ឋានឥណទាន

លោក ហេង សក្តា ជាសមាជិកដែលបានធ្វើការយូរជាងគេជាមួយ ហ្វីស ហ្វាយនែន ។ ចាប់ផ្តើមដំបូងជាមន្រ្តីរដ្ឋបាលឥណទាននៅឆ្នាំ 2009 ពេលដែល ហ្វីស ហ្វាយនែន ទទួលបានអាជ្ញាប័ណ្ណ របស់ខ្លួន ។ លោក សក្តា បានរីកចម្រើនជាមួយតួនាទីមួយចំនួន និងបានទទួលការតែងតាំងជាប្រធានសាខាភ្នំពេញនៅឆ្នាំ 2013 និងជាប្រធាននាយ-កដ្ឋានប្រតិបត្តិការនៅខែ ឧសភា ឆ្នាំ 2015។ គាត់មានចំណេះដឹងទូលំទូលាយអំពីក្រុងភ្នំពេញ ព្រោះគាត់រស់នៅទីនេះពេញមួយជីវិតរបស់គាត់ តែគាត់ក៏មានបទពិសោធន៍ ធ្វើដំណើរទៅក្រៅប្រទេសផងដែរ ។ លោក សក្តា ទទួលបានបរិញ្ញាបត្រពីរ គឺគណនេយ្យហិរញ្ញវត្ថុ និង ភាសាបារាំង ។ បច្ចុប្បន្នគាត់កំពុងបញ្ចប់អនុបណ្ឌិតគ្រប់គ្រងហានិភ័យ ផ្នែកធានារ៉ាប់រង ហិរញ្ញវត្ថុ និងធនាគារ ។

## ឆេង ប៊ុនហៀង
### ប្រធាននាយកដ្ឋានគ្រប់គ្រងផ្នែកលក់

លោក ប៊ុនហៀង បានចូលបម្រើការនៅ ហ្វីស ហ្វាយនែន នៅខែវិច្ឆិកា ឆ្នាំ 2018 ជាប្រធានគ្រប់គ្រងផ្នែកលក់។ គាត់បានចាប់ផ្តើមការងារនៅ អម្រឹតក្នុងឆ្នាំ 2003 ដែលទីនោះគាត់បានធ្វើការនៅក្នុងថ្នាក់គ្រប់គ្រងរយៈពេល 10ឆ្នាំ ។ ប្រវត្តិការងាររបស់លោកបានចាប់ផ្តើមពីថ្នាក់មូលដ្ឋាន គឺចាប់ពីតួនាទីជាអ្នកបើកបរ បេឡា បុគ្គលិកឥណទាន អនុប្រធានសាខា ប្រធានសាខា និងអនុប្រធានសាខាខេត្ត ប្រធានសាខាខេត្ត និងអនុប្រធានអភិវឌ្ឍផលិតផលឥណទាន ។
លោក ប៊ុនហៀង បានបញ្ចប់បរិញ្ញាបត្រផ្នែករដ្ឋបាលពាណិជ្ជកម្ម ជំនាញគណនេយ្យ និងហិរញ្ញវត្ថុក្នុងឆ្នាំ 2007 ពីសាកលវិទ្យាល័យ បៀលប្រាយ និងភាសាអង់គ្លេសពីសាកលវិទ្យាល័យបញ្ញាសាស្រ្ត។



## វ៉ែត វរលក្ខណ៍
### ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ

អ្នកស្រី វរលក្ខណ៍ មានបទពិសោធន៍ជាង10ឆ្នាំ ផ្នែកគណនេយ្យ និងហិរញ្ញវត្ថុ ។ វរលក្ខណ៍ ធ្លាប់បម្រើការងារនៅតាមក្រុមហ៊ុនគណនេយ្យ ក្រុមហ៊ុនធានារ៉ាប់រង និងអាជីវកម្មទូទៅ ។ អ្នកស្រី ចូលបម្រើការងារនៅក្នុង ហ្វីស ហ្វាយនែន នាឆ្នាំ2012 ។ វរលក្ខណ៍ បានបញ្ចប់ថ្នាក់បរិញ្ញាប័ត្រ ផ្នែកហិរញ្ញវត្ថុ និងធនាគារ អនុបណ្ឌិតផ្នែកគ្រប់គ្រងពាណិជ្ជកម្ម និង បច្ចុប្បន្នកំពុងបន្តការសិក្សាថ្នាក់ ACCA ។



## សាំង វណ្ណឌី
### ប្រធាននាយកដ្ឋានទីផ្សារ

លោក វណ្ណឌី បានបញ្ចប់បរិញ្ញាបត្រផ្នែកប្រព័ន្ធព័ត៌-មានវិទ្យាគ្រប់គ្រង ពីសាកលវិទ្យាល័យជាតិគ្រប់-គ្រងក្នុងឆ្នាំ2002។ មុនមកចូលរួមជាមួយ ហ្វីស ហ្វាយនែន គាត់បានបំរើការជាអ្នកសម្របសម្រួលផ្នែកទីផ្សារ និងទំនាក់ទំនងរយៈពេល 2ឆ្នាំ និងបន្ទាប់មកជាអ្នកគ្រប់គ្រងផ្នែកផលិតសម្ភារៈផ្សព្វផ្សាយជាង 7 ឆ្នាំ នៅ វីសិនហ្វាន់ កម្ពុជា ដែលគាត់ជាអ្នកគ្រប់គ្រង និងអភិវឌ្ឍន៍យុទ្ធសាស្ត្រប្រេនដ៍ និងយុទ្ធសាស្ត្រទំនាក់ទំនងទីផ្សារ។ លោក វណ្ណឌី ក៏មានបទពិសោធន៍ជាច្រើនឆ្នាំ ជាមួយក្រុមហ៊ុនផ្សព្វផ្សាយពាណិជ្ជកម្ម និងអង្គការអន្តរជាតិផងដែរ ។ គាត់ចូលរួមជាមួយ ហ្វីស ហ្វាយនែន ក្នុង ខែមីនា ឆ្នាំ 2016 ជាប្រធានផ្នែកទីផ្សារ ។



## ច្រឹក ស៊ីណេត
### ប្រធាននាយកដ្ឋានព័ត៌មានវិទ្យា

លោក ស៊ីណេត បានបម្រើការអស់រយៈពេលច្រើនជាងមួយទសវត្សរ៍ ហើយក្នុងកិច្ចការអនុវត្តប្រព័ន្ធបណ្តាញកុំព្យូទ័រ ប្រព័ន្ធសុវត្ថិភាពព័ត៌មានវិទ្យា ប្រព័ន្ធគ្រប់គ្រងព័ត៌មាន ក៏ដូចជាការងារយុទ្ធសាស្ត្រ និងគម្រោងព័ត៌មានវិទ្យាផ្សេងៗ ជាមួយស្ថាប័នមីក្រូហិរញ្ញវត្ថុ ។ គាត់បានចូលរួមជាមួយ ហ្វីស ហ្វាយនែន ជាប្រធានផ្នែកព័ត៌មានវិទ្យា នាខែមេសា ឆ្នាំ 2016 ។ កាលពីមុន គាត់ធ្លាប់ជាប្រធានគាំទ្រកម្មវិធីព័ត៌មានវិទ្យា ដែលមានតួនាទីសម្របសម្រួលរវាងបុគ្គលិក បច្ចេកទេស ព័ត៌មានវិទ្យា និងបុគ្គលិកផ្នែកអាជីវកម្មនៅអម្រឹត និងធ្លាប់ជាប្រធានគាំទ្រកម្មវិធី និងបច្ចេកទេសនៅ វីសិនហ្វាន់កម្ពុជា។ គាត់បានទទួលបរិញ្ញាបត្រព័ត៌មានវិទ្យា ពីសាកលវិទ្យាល័យបៀលប្រាយ នៅទីក្រុងភ្នំពេញ។

# គណៈគ្រប់គ្រង





## ស៊ាន ម៉េងសែ

### ប្រធាននាយកដ្ឋាន
### រដ្ឋបាលនិងធនធានមនុស្ស

លោក ម៉េងសែ មានការរីកចម្រើនខ្ពស់ក្នុងអាជីពការងារ ។ លោកបានប្រលូកចូលក្នុងវិស័យការងារបានជាង 10 ឆ្នាំ ដោយចាប់ផ្តើមពីកម្រិតបុគ្គលិកធម្មតា រហូតដល់កម្រិតគ្រប់គ្រងក្នុងផ្នែកបណ្តុះបណ្តាល និងអភិវឌ្ឍន៍ និងផ្នែកគ្រប់គ្រងធនធានមនុស្ស ដោយលោកមានបទពិសោធន៍ និងជំនាញពាក់ព័ន្ធនឹងផ្នែកជ្រើសរើសបុគ្គលិក បង្កើតគោលនយោបាយធនធានមនុស្ស រដ្ឋបាលបុគ្គលិក សម្របសម្រួលកិច្ចការធនធានមនុស្ស សំណងទូទាត់ ។ល។ លោកមានអត្តចរិតល្អប្រសើរ មានភាពអត់ធ្មត់ និងការតាំងចិត្តខ្ពស់។ អំពីការសិក្សា លោកបានទទួលអាហារូបករណ៍កម្រិតបរិញ្ញាបត្រពីសាកលវិទ្យាល័យជាតិគ្រប់គ្រងក្នុងឆ្នាំ 2000 និងបានបញ្ចប់បរិញ្ញាបត្រផ្នែកគ្រប់គ្រងក្នុងឆ្នាំ 2004 និងបញ្ចប់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងក្នុងឆ្នាំ 2009 ។

## ហួ ណាំគា

### ប្រធាននាយកដ្ឋានសវនកម្មផ្ទៃក្នុង

លោក ណាំគា មានបទពិសោធន៍ជាង 10 ឆ្នាំ ផ្នែកសវនកម្ម និងហិរញ្ញវត្ថុ ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ ជាមួយក្រុមហ៊ុនប្រឹក្សាយោបល់ និងក្រុមហ៊ុនអន្តរជាតិ ។ បទពិសោធន៍របស់គាត់ គឺពាក់ព័ន្ធនឹងការត្រួតពិនិត្យ វាយតម្លៃ និងផ្តល់យោបល់ លើការគ្រប់គ្រងហានិភ័យ ការត្រួតពិនិត្យផ្ទៃក្នុង អភិបាលកិច្ច និងស៊ើបអង្កេតលើការកេងបន្លំនៅក្នុងស្ថាប័ន ។ មុនពេលចូលរួមជាមួយ ហ្វីស ហ្វាយនែន លោកបានកាន់តួនាទីជាច្រើនរួមមាន ប្រធានផ្នែកសវនកម្ម អនុប្រធានត្រួតពិនិត្យហិរញ្ញវត្ថុ និងតួនាទីមួយចំនួនក្នុងតំណែងគ្រប់គ្រង ។

លោក ណាំគា បានបញ្ចប់បរិញ្ញាបត្រផ្នែកធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ហើយគាត់កំពុងបន្តការបញ្ចាក់ពីគុណវុឌ្ឍិសវនកម្មរបស់គាត់ផងដែរ ។

លោក ហួ ណាំគា បានចូលបម្រើការនៅ ហ្វីស ហ្វាយនែន ជាប្រធានផ្នែក សវនកម្មផ្ទៃក្នុង នៅខែមិថុនា ឆ្នាំ 2018 ។



សម្រាប់ ហ្វឹស ហ្វាយនៃន
ការមានលំនៅដ្ឋានផ្ទាល់ខ្លួន
គឺជាសិទ្ធិសកល និងជាកត្តា
ចូលរួមចំណែកក្នុងការកាត់បន្ថយ
ភាពក្រីក្រផងដែរ

# ការិយាល័យកណ្ដាល

អគារលេខ 15-17 ផ្លូវ 271 សង្កាត់
ទំនប់ទឹក ខណ្ឌចំការមន រាជធានី ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
( ក្បៀរផ្សារទំនើប សុវណ្ណា )

093 666 635
www.firstfinance.biz
firstfinance